ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ០១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី

## ការកាត់ដីទំហំ ២ ៩៦៧ ហិកតា នៅស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ចេញពីដីអតីតសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន តាពីម៉ិច និងចេញពីដីគម្របព្រៃឈើ ឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនបញ្ជាការដ្ឋានកាំភ្លើងធំ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ និងជូនប្រជាពលរដ្ឋចំនួន ៩៤ គ្រួសារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យ ប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ១៥១២ សជណ ចុះថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ៤៩៣/១៧ ល.ស ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៧ របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង
- លិខិតលេខ ២៤៣០ ដនស/អសក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៧ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតលេខ ៩៦៧៥ កសក ចុះថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១** : ត្រូវបានកាត់ផ្ទៃដីទំហំ ២ ៩៧៥ ហិកតា ចេញពីអតីតសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ភាពីម៉ិច និងចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ក្នុងនោះទំហំ ២ ៧៣៧ ហិកតា សម្រាប់បង្កើតទីលានបាញ់គ្រាប់ពិតកាំភ្លើងធំគ្រប់ប្រភេទ ទីតាំងឈរជើងវរសេនាតូចកាំភ្លើងធំលេខ ៨២ ៨៣ ៨៥ និងតំបន់អភិវឌ្ឍន៍របស់បញ្ជាការដ្ឋានកាំភ្លើងធំ អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ និង**ទំហំ ២២០ ហិកតា** ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ជាំដុះដាក់ស្តែង និងរក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅ**ភូមិដំណាក់អំពិល ឃុំក្រាំងស្គារ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង** តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ២** : ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនបញ្ជាការ

ដ្ឋាន អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ និងជូនប្រជាពលរដ្ឋ ចំនួន ៩៤ គ្រួសារ នៅភូមិដំណាក់អំពិល ឃុំក្រាំងស្គារ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ។

**មាត្រា ៣** : ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម និងអនុវត្តការចុះបញ្ជីដី រួចលើកសំណើសុំផ្តល់សិទ្ធិលើក្បាលដី តាមគោលការណ៍ និងនីតិវិធីជាធរមាន ។

**មាត្រា ៤** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃពុធ ២ រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែមករា ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**រូបសណ្ឋានភ្ជាប់អនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ២០១៨ ស្តីពីការកាត់ផ្ទៃដីទំហំ ២៩៥៧ ហិកតា នៅស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ចេញពីតំបន់សម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនគាំពិម៉ិចនិងជីតាំបេព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋជូនបញ្ជាការដ្ឋានកាំភ្លើងធំទំហំ ២៧៣៧ ហិកតា និងធ្វើប្រទានកម្មជូនប្រជាពលរដ្ឋទំហំ ២២០ ហិកតា**

| Id | X | Y |
|---|---|---|
| 1 | 427205 | 1348983 |
| 2 | 430137 | 1347382 |
| 3 | 425299 | 1342086 |
| 4 | 424637 | 1342070 |
| 5 | 424374 | 1341769 |
| 6 | 422998 | 1341126 |
| 7 | 422185 | 1341090 |
| 8 | 422080 | 1341467 |
| 9 | 421367 | 1341950 |
| 10 | 420971 | 1342416 |

